**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣✻៤

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
លេខ ០០៩ ស.អ.យ.

ថ្ងៃ សុក្រ ៨កើត ខែ កត្តិក ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ ២០២១

# សេចក្តីណែនាំ
# ស្តីពី
# តួនាទី និងភារកិច្ចសម្រាប់មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច
# ក្រុង ស្រុក ខណ្ឌ

យោងតាមឧបសម្ព័ន្ធទី១(ដ)វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃអនុក្រឹត្យលេខ ១៨២ អនក្រ.បក ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង អនុក្រឹត្យលេខ១៨៣ អនក្រ.បក ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ និងអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ស្តីពីមុខងារ និង រចនាសម្ព័ន្ធរដ្ឋបាលស្រុក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ បានកំណត់ពីមុខងារ ចំនួន៧រួមមានៈ (១)ការងារ កុមារកំព្រានិងកុមាររងគ្រោះ (២)ការងារជនរងគ្រោះនិងងាយរងគ្រោះ (៣)ការងារជនពិការ (៤)ការងារ បេឡាជាតិអតីតយុទ្ធជន និងបេឡាជាតិសន្តិសុខសង្គម (៥)ការងារអតីតយុទ្ធជននិងគ្រួសារ (៦)ការងារ មណ្ឌលស្តារនីតិសម្បទា (៧)ការងារសមាគមមនុស្សវ័យចាស់។ មាត្រា ៦ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ ប្រគល់មុខងារ "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែន រដ្ឋាភិបាល" ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក។

ដើម្បីអនុវត្តមុខងារខាងលើ និងយោងលិខិតលេខ១៣៩ លស/អរប ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្តីពីសំណើសុំតែងតាំងមន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន០១រូប មកពីការិយាល័យ សង្គមកិច្ចនិងសុខុមាលភាពសង្គមឱ្យទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ធ្វើការណែនាំស្តីអំពីតួនាទីនិងភារកិច្ច សម្រាប់មន្ត្រីរដ្ឋបាលក្រុង ស្រុក ដែលបានតែងតាំងជា "បុគ្គលិកសង្គមកិច្ច" ដែលជា"អ្នកអាជីពសង្គមកិច្ចរង Para-Professional Social Worker" មានដូចខាងក្រោមៈ

- ផ្សព្វផ្សាយគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងលើកកម្ពស់ការយល់ដឹងអំពីការបង្ការ ទប់ស្កាត់ ការឆ្លើយតបចំពោះ អតិថិជនដែលជាជនរងគ្រោះ និងងាយរងគ្រោះ ។
- រៀបចំផែនទីសេវា និងកៀរគរធនធានពីស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ពាក់ ព័ន្ធនានាដើម្បីផ្តល់កិច្ចគាំទ្រចាំបាច់ដល់អតិថិជន និងបញ្ជូនអតិថិជនឱ្យទៅទទួលសេវាទៅតាម តម្រូវការចាំបាច់។



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambobodia. Fax/Phone: (855) 23 726086

- សហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត អង្គភាព និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីរៀបចំបណ្តុះបណ្តាល និងផ្តល់បច្ចេកទេសពាក់ព័ន្ធនឹងការងារសង្គមកិច្ចដល់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ (គ.ក.ន.ក)។
- គ្រប់គ្រង និងវិភាគទិន្នន័យ អតិថិជន នៅក្នុងដែនសមត្ថកិច្ចរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានជាអាទិ៍ កុមារកំព្រា កុមាររងគ្រោះ និងងាយរងគ្រោះ កុមារដែលកំពុងស្ថិតនៅក្នុងការថែទាំជំនួស អនីតិជនដែលប្រព្រឹត្តអំពើល្មើសច្បាប់ អ្នកញៀនគ្រឿងញៀន ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជនចំណាកស្រុក គ្រួសារទីទ័លក្រ ជនចាស់ជរាគ្មានទីពឹង ជនអនាថា ជនវិបល្លាសស្មារតី អ្នកផ្ទុកមេរោគអេដស៍ ជនមានពិការភាព ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំនៃគ្រួសារក្រីក្រ និងប្រជាជនរងគ្រោះដោយគ្រោះមហន្តរាយ។ល។
- គ្រប់គ្រងករណីអតិថិជនដោយអនុវត្តតាមនីតិវិធីគ្រប់គ្រងករណី ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានវិទ្យា ដូចជាប្រព័ន្ធ Primero ឬប្រព័ន្ធផ្សេងទៀតដែលមាន។
- ត្រួតពិនិត្យមណ្ឌលថែទាំអតិថិជនរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចក្រុង ស្រុក និងខណ្ឌ។
- ចុះកំណត់អត្តសញ្ញាណ ជ្រើសរើស ប៉ាន់ប្រមាណ និងធ្វើការសម្រេចចិត្តបិទ ឬបន្តករណីកុមារដែលស្ថិតក្រោមការថែទាំដោយសាច់ញាតិ ដោយឈរលើឧត្តមប្រយោជន៍ និងមិនបង្កការឈឺចាប់ដល់កុមារ ដោយសហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ និងអង្គការដៃគូពាក់ព័ន្ធ។
- តាមដានករណីកុមារដែលទទួលបានសេវាថែទាំជំនួសដោយឪពុកម្តាយធម៌ ការថែទាំដោយគ្រួសារសាច់ញាតិលក្ខណៈផ្លូវការ ការរស់នៅឯករាជ្យលក្ខណៈផ្លូវការ កុមារដែលកំពុងស្នាក់នៅក្នុងកន្លែងថែទាំឬកុមារប្រឈមទៅនឹងការបំបែកពីគ្រួសារដោយមិនចាំបាច់ និងកុមារដែលត្រូវការការរៀបចំផែនការអចិន្ត្រៃយ៍។
- ចូលរួមបង្ការ ទប់ស្កាត់ និងការឆ្លើយតបចំពោះអំពើហិង្សា អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការរំលោភបំពានគ្រប់ទម្រង់ផ្សេងៗទៀត និងស្ថានភាពវិបត្តិ/ស្ថានភាពអាសន្នផ្សេងៗ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ។
- តាមដានអនីតិជនដែលបានទទួលកម្មវិធីបង្វែរ ការស្តារនីតិសម្បទា និងក្រោយពេលសមាហរណកម្មទៅគ្រួសារ និងសហគមន៍។
- សម្របសម្រួលការងារអភិវឌ្ឍអតីតយុទ្ធជននៅតាមសហគមន៍ និងគាំទ្របច្ចេកទេសដល់សមាគមអតីតយុទ្ធជន ឃុំ សង្កាត់។
- សម្របសម្រួលនិងតាមដានការងារថែទាំមនុស្សវ័យចាស់នៅតាមសហគមន៍ និងពង្រឹងសមត្ថភាពសមាគមមនុស្សវ័យចាស់ ឃុំ សង្កាត់។
- សម្របសម្រួលក្នុងការអនុវត្តកម្មវិធីជំនួយសង្គមផ្សេងៗ។

មន្ត្រីនៃការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានតែងតាំងជា "បុគ្គលិកសង្គមកិច្ច"ដែលជា"អ្នកអាជីពសង្គមកិច្ចរង Para-Professional Social Worker" ក្រុង ស្រុក ខណ្ឌ នឹងទទួលបានការបណ្តុះបណ្តាលពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃដើម្បីអនុវត្តតួនាទីនិងភារកិច្ចដូចខាងលើឱ្យមានប្រសិទ្ធភាព គណនេយ្យភាពនិងទទួលបានប្រសិទ្ធផលខ្ពស់។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងមហាផ្ទៃ ដើម្បីរៀបចំសៀវភៅណែនាំស្តីពីការអនុវត្តមុខងារដូចមានចែងនៅក្នុងនៅឧបសម្ព័ន្ធទី១(ង) វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៃអនុក្រឹត្យលេខ ១៨២ ១៨៣ ១៨៤ និងមាត្រា ៦ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក។

ទទួលបានសេចក្តីណែនាំនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត នាយកដ្ឋាន និងអង្គភាពចំណុះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ត្រីដែលទទួលបានការតែងតាំងជា "បុគ្គលិកសង្គមកិច្ច" ដែលជា "អ្នកអាជីពសង្គមកិច្ចរង Para-Professional Social Worker" សូមចូលរួមសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់។

**រដ្ឋមន្ត្រី**

វង សូត

**ទីកន្លែងទទួល៖**

- ក្រសួងមហាផ្ទៃ
- រដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- នាយកដ្ឋាន និងអង្គភាពចំណុះក្រសួង ស.អ.យ
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
  " ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ